KB PRASAC Bank

ធនាគារ ខេប៊ីប្រាសាក់ ម.ក

លក្ខខណ្ឌនៃការប្រើប្រាស់ សេវាខេប៊ីប្រាសាក់ខបតើរេត

Terms and Conditions of Using KB PRASAC Corporate

ចោះពុម្ពលើកទី ១

មាតិកា

1. សេចក្តីផ្តើម....1
2. និយមន័យនៃពាក្យគន្លឹះ....1
3. ប្រភេទមុខងារសំខាន់ៗនៃសេវាខេប៊ីប្រាសាក់ខបភើរេត....3
4. ការស្នើសុំប្រើប្រាស់សេវាខេប៊ីប្រាសាក់ខបភើរេត....4
   - 4.1. លក្ខខណ្ឌនៃការស្នើសុំប្រើប្រាស់សេវាខេប៊ីប្រាសាក់ខបភើរេត....4
   - 4.2. ប្រភេទអ្នកប្រើប្រាស់ សេវាខេប៊ីប្រាសាក់ខបភើរេត (Type of User)....5
   - 4.3. ការកំណត់បន្ទាត់អនុម័តប្រតិបត្តិការ (Authorization Line)....5
   - 4.4. ការបើកដំណើរការសេវាខេប៊ីប្រាសាក់ខបភើរេត (Activate KB PRASAC Corporate)....5
   - 4.5. ការចូលប្រើប្រាស់សេវាខេប៊ីប្រាសាក់ខបភើរេត....6
   - 4.6. ការស្នើសុំភ្ជាប់គណនីបញ្ជើសន្សំ....6
   - 4.7. ការស្នើសុំដកគណនីបញ្ជើសន្សំ....6
   - 4.8. ការស្នើសុំភ្ជាប់គណនីបញ្ជើមានកាលកំណត់....6
   - 4.9. ការស្នើសុំភ្ជាប់គណនីកម្ចី....6
   - 4.10. ការស្នើសុំលេខកូដសម្ងាត់ថ្មីករណីភ្លេច (Password) និង/ឬ អត្តលេខអ្នកប្រើប្រាស់ (User ID)....7
   - 4.11. ការស្នើសុំកែប្រែព័ត៌មានអ្នកប្រើប្រាស់ និង/ឬ សិទ្ធិអ្នកប្រើប្រាស់សេវាខេប៊ីប្រាសាក់ខបភើរេត....7
5. កម្រិតសិទ្ធិប្រើប្រាស់គណនីភ្ជាប់សេវាខេប៊ីប្រាសាក់ខបភើរេត....7
6. ម៉ោងប្រតិបត្តិការ....7
7. រូបិយប័ណ្ណ និងអត្រាប្តូរប្រាក់....7
8. ទំហំកំណត់នៃប្រតិបត្តិការ និងកម្រៃសេវា....8
9. សារជូនដំណឹងស្តីពីប្រតិបត្តិការកើតឡើងក្នុងគណនី (Push Notification)....8
10. លក្ខណៈពិសេសផ្សេងៗពីប្រតិបត្តិការតាមរយៈសេវាខេប៊ីប្រាសាក់ខបភើរេត....8
11. ការស្នើសុំបង្ខាំង ឬ ដោះបង្ខាំងសេវាខេប៊ីប្រាសាក់ខបភើរេត....8
12. ការបញ្ឈប់ការប្រើប្រាស់សេវាខេប៊ីប្រាសាក់ខបភើរេត....8
13. សុវត្ថិភាពលើការប្រើប្រាស់សេវាខេប៊ីប្រាសាក់ខបភើរេត....9
14. សិទ្ធិ និងកាតព្វកិច្ចរបស់អតិថិជន....11
15. សិទ្ធិ និងកាតព្វកិច្ចរបស់ខេប៊ីប្រាសាក់....12
16. ការកែប្រែកម្រៃសេវា ទំហំកំណត់ លក្ខខណ្ឌផ្សេងៗ និងការជូនដំណឹង....13
17. ការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម....14
18. ច្បាប់ និងការដោះស្រាយវិវាទ....14
19. វិភាគភាព....14
20. ភាសា....14

1. សេចក្តីផ្តើម

1.1. លក្ខខណ្ឌនៃការប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេត (KB PRASAC Corporate) តទៅហៅថា **«លក្ខខណ្ឌប្រើប្រាស់»** គឺជាកិច្ចព្រមព្រៀងរវាង **លោក-លោកស្រី** ជាមួយ ធនាគារ ខេប៊ីប្រាសាក់ ម.ក តទៅហៅថា **«ខេប៊ីប្រាសាក់»** ទាក់ទងទៅនឹងការប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេត។

1.2. សូម លោក-លោកស្រី អាន **លក្ខខណ្ឌប្រើប្រាស់** នេះដោយប្រុងប្រយ័ត្ន មុននឹង**លោក-លោកស្រី**យល់ព្រមបំពេញពាក្យស្នើសុំប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេត។

1.3. នៅពេល លោក-លោកស្រី បានបំពេញ និងចុះហត្ថលេខា ឬ ផ្តិតស្នាមមេដៃលើពាក្យស្នើសុំប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេត នោះសបញ្ជាក់ថា លោក-លោកស្រី បានអាន បានយល់ និងព្រមអនុវត្តនូវគ្រប់លក្ខខណ្ឌទាំងអស់ ដែលបានចែងនៅក្នុងលក្ខខណ្ឌប្រើប្រាស់នេះ រួមទាំង «លក្ខខណ្ឌទូទៅនៃការប្រើប្រាស់ផលិតផល និងសេវាកម្ម របស់ខេប៊ីប្រាសាក់» ហើយ លោក-លោកស្រី យល់ព្រមទទួលខុសត្រូវទាំងស្រុងលើប្រតិបត្តិការដែលធ្វើតាមរយៈសេវាខេប៊ីប្រាសាក់ឧបភើរេត។

2. និយមន័យនៃពាក្យគន្លឹះ

- **ពាក្យ «លោក-លោកស្រី»** ៖ សំដៅដល់អតិថិជនជា ម្ចាស់គណនី ឬ អ្នកមានសិទ្ធិនៅក្នុងគណនី ឯកត្តជន ឬ នីតិបុគ្គល ឬ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលបានចុះឈ្មោះប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេត។
- **សេវាខេប៊ីប្រាសាក់ឧបភើរេត** ៖ សំដៅលើ សេវាមួយប្រភេទដែលអនុញ្ញាតឱ្យ លោក-លោកស្រី អាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ លើគណនីរបស់ខ្លួនបានដោយសុវត្ថិភាពនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា (24/7) តាមរយៈ៖
  - **ខេប៊ីប្រាសាក់ឧបភើរេតវេប** (KB PRASAC Corporate Web) សម្រាប់អតិថិជនប្រើប្រាស់តាមរយៈ Internet Browser ដូចជា Google Chrome, Microsoft Edge, Apple Safari... ដើម្បីធ្វើប្រតិបត្តិការហិញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុនៅលើគណនីរបស់ខ្លួន និង
  - **ខេប៊ីប្រាសាក់ឧបភើរេតអេប** (KB PRASAC Corporate App) សម្រាប់ អតិថិជនប្រើប្រាស់តាមរយៈកម្មវិធី ដែលទាញចេញពី App Store ឬ Play Store នៅក្នុងទូរស័ព្ទដៃ (Smart Phone) ប្រើប្រាស់សម្រាប់ទទួល **លេខកូដ** OTP ដើម្បីចូលប្រើប្រាស់ និងអនុម័តលើប្រតិបត្តិការដែលបានធ្វើនៅក្នុង **ខេប៊ីប្រាសាក់ឧបភើរេតវេប** (KB Corporate Web)។

- **លេខកូដ OTP** ៖ មានពាក្យពេញ One-Time Password ជាលេខកូដសម្ងាត់ចំនួន 06 **ខ្ទង់** ដែលត្រូវបានបង្កើតឡើងដោយស្វ័យប្រវត្តិពី «ខេប៊ីប្រាសាក់ឧបភើរេតអេប (KB PRASAC Corporate App)» និងត្រូវប្រើដើម្បីចូលប្រើប្រាស់សេវា និង/ឬ អនុម័តលើ ប្រតិបត្តិការផ្សេងៗនៅក្នុង «ខេប៊ីប្រាសាក់ឧបភើរេតវេប (KB PRASAC Corporate Web)»។ **លេខកូដ OTP** នេះមានសុពលភាពប្រើប្រាស់បានតែមួយដង ឬ មួយប្រតិបត្តិការគត់។
- **គណនី** ៖ សំដៅលើគណនីប្រាក់បញ្ញើសន្សំទាំងឡាយណាដែល លោក-លោកស្រីបានបើកជាមួយ ធនាគារ ខេប៊ីប្រាសាក់ ម.ក អាចជា គណនីសន្សំ ឬ គណនីចរន្ត និងគណនីផ្សេងៗ ដែលអនុញ្ញាតនៅពេលស្នើសុំ។ល។
- **គណនីនីតិបុគ្គល** ៖ ជាប្រភេទគណនី បើកជូនអតិថិជនប្រភេទជាក្រុមហ៊ុន អង្គការ ស្ថាប័ន ប្រើប្រាស់ដើម្បីធ្វើប្រតិបត្តិការទៅតាមតម្រូវការជាក់ស្តែង។
- **គណនីឯកត្តជន** ៖ ជាប្រភេទគណនី សម្រាប់បើកជូនអតិថិជនជារូបវន្តបុគ្គលប្រើប្រាស់ដើម្បីធ្វើប្រតិបត្តិការទៅតាមតម្រូវការផ្ទាល់ខ្លួន។
- **គណនីឯកត្តជនផ្ទាល់ខ្លួន** ៖ ជាប្រភេទគណនីឯកត្តជន ដែលមានម្ចាស់គណនីតែម្នាក់គត់។
- **គណនីឯកត្តជនរួម** ៖ ជាប្រភេទគណនីឯកត្តជន ដែលមានសមាជិករួមគណនី (គណនី) ចាប់ពី 02នាក់ ឡើងទៅ។
- **អត្តលេខអ្នកប្រើប្រាស់ (User ID)** ៖ ជាអត្តលេខសម្គាល់អ្នកប្រើប្រាស់ មានចំនួនចាប់ 08 ទៅ **16ខ្ទង់** ដែលបង្កើតសម្រាប់ចូលប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេត។
- **លេខសម្ងាត់ (Password)** ៖ គឺជាលេខសម្ងាត់ផ្ទាល់ខ្លួនមានចំនួនចាប់ពី 8 ទៅ 16 ខ្ទង់ ដែលត្រូវបានកំណត់ដោយផ្ទាល់ពី លោក-លោកស្រី សម្រាប់ចូលប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេត។
- **ការស្កេនស្នាមខ្ទៅដៃ/ផ្ទៃមុខ** ៖ សំដៅដល់ប្រព័ន្ធសុវត្ថិភាពនៃការស្កេនស្នាមខ្ទៅដៃ ឬ ផ្ទៃមុខនៅលើទូរស័ព្ទចល័ត (Fingerprint / Facial Recognition) សម្រាប់បញ្ជាក់អត្តសញ្ញាណអតិថិជននៅពេលចូលទៅប្រើ «ខេប៊ីប្រាសាក់ឧបភើរេតអេប/KB PRASAC Corporate App» បន្ថែមពីលើការប្រើប្រាស់ **លេខកូដសម្ងាត់ (Password)**។ លោក-លោកស្រី អាចកំណត់ការចូលទៅប្រើប្រាស់ខេប៊ីប្រាសាក់ឧបភើរេតអេប ដោយប្រើការស្កេនស្នាមខ្ទៅដៃ/ផ្ទៃមុខ លុះត្រាតែលោក-លោកស្រី បានកំណត់ លក្ខខណ្ឌសុវត្ថិភាពនេះសម្រាប់ការចូលទៅប្រើប្រាស់ទូរស័ព្ទចល័តរបស់ លោក-លោកស្រី ជាមុន។
- **ប្រតិបត្តិការស្វ័យប្រវត្តិ (Straight Through Process)** ៖ ជាប្រតិបត្តិការបានសម្រេចភ្លាមៗ បន្ទាប់ពីប្រតិបត្តិការនោះបានបញ្ចូលនិងអនុម័តដោយ លោក-លោកស្រី ដោយមិនតម្រូវឱ្យឆ្លងកាត់ការត្រួតពិនិត្យ និងការអនុម័តពី ខេប៊ីប្រាសាក់ ឡើយ។

- **ប្រតិបត្តិការមិនស្វ័យប្រវត្តិ (Non-Straight Through Process)** ៖ ជាប្រតិបត្តិការ ដែលលោក-លោកស្រីបញ្ចូល និងអនុម័តរួចរាល់ ប៉ុន្តែតម្រូវឱ្យឆ្លងកាត់ការត្រួតពិនិត្យ និងការអនុម័តពី ខេប៊ីប្រាសាក់ ដើម្បីឱ្យប្រតិបត្តិការសម្រេចបានជោគជ័យ។
- **បន្ទាត់អនុម័តប្រតិបត្តិការ (Authorization Line)** ៖ ជាលក្ខខណ្ឌប្រើប្រាស់សេវាខេប៊ីប្រាសាក់ខបភើរេត ដោយមានអ្នកប្រើប្រាស់ច្រើន (User) ដូចជា៖
  - អ្នកធ្វើប្រតិបត្តិការ (Maker)
  - អ្នកត្រួតពិនិត្យ (Checker)
  - អ្នកអនុម័ត (Authorizer) និង
  - អ្នកអនុម័តចុងក្រោយ (Final Authorizer) ហើយគ្រប់ប្រតិបត្តិការទាំងអស់ គឺត្រូវចាប់ផ្តើមពី អ្នកធ្វើប្រតិបត្តិការ (Maker) និងបញ្ចប់ប្រតិបត្តិការដោយ អ្នកអនុម័តចុងក្រោយ (Final Authorizer)។
- Non-Authorization Line ៖ ជាលក្ខខណ្ឌប្រើប្រាស់សេវាខេប៊ីប្រាសាក់ខបភើរេត ដោយមានអ្នកប្រើប្រាស់តែម្នាក់ ហើយគ្រប់ប្រតិបត្តិការទាំងអស់គឺចាប់ផ្តើម និងបញ្ចប់ប្រតិបត្តិការដោយ អ្នកប្រើប្រាស់តែម្នាក់ប៉ុណ្ណោះ។
- **របាយការណ៍គណនី (Bank Statement)** ៖ គឺជាកំណត់ត្រានៃប្រតិបត្តិការចេញ ឬ ចូលនៅក្នុងគណនី ដែលលោក-លោកស្រីអាចពិនិត្យតាមរយៈសេវាខេប៊ីប្រាសាក់ខបភើរេត។
- **ករណីប្រធានសក្តិ** ៖ សំដៅលើអំពើទាំងឡាយណា ដែលកើតឡើងក្រៅពីឆន្ទៈ ដោយមិនអាចប៉ាន់ស្មានជាមុន និងមិនអាចជំនះបាន ឬ ដែលមិនអនុញ្ញាតឱ្យភាគីណាមួយ ឬ ទាំងពីរអាចបន្តបំពេញកាតព្វកិច្ចរបស់ខ្លួនជាប្រក្រតីបានដូចជា៖ បន្ទុះភ្នំភ្លើង ទឹកជំនន់ គ្រោះរញ្ជួយដី ព្យុះសង្ឃរា ភេរវកម្ម កុបកម្ម សង្គ្រាម។ល។

3. ប្រភេទមុខងារសំខាន់ៗនៃសេវាខេប៊ីប្រាសាក់ខបភើរេត

- ផ្ទេរប្រាក់រវាងគណនីផ្ទាល់ខ្លួន នៅខេប៊ីប្រាសាក់
- ផ្ទេរប្រាក់ពីគណនី ទៅ គណនីផ្សេង នៅខេប៊ីប្រាសាក់
- ផ្ទេរប្រាក់ពីគណនី ទៅ គណនីនៅធនាគារផ្សេងក្នុងប្រទេស
- ផ្ទេរប្រាក់ពីគណនី ទៅគណនី នៅខេប៊ីប្រាសាក់ (ជាកញ្ចប់)
- ផ្ទេរប្រាក់អន្តរជាតិ (តាមប្រព័ន្ធ SWIFT)
- ស្នើសុំកែប្រែព័ត៌មាននៃការផ្ទេរប្រាក់អន្តរជាតិតាមរយៈប្រព័ន្ធ SWIFT
- ស្នើសុំមោឃភាពនៃការផ្ទេរប្រាក់អន្តរជាតិតាមរយៈប្រព័ន្ធ SWIFT
- ការបើកប្រាក់បៀវត្ស
- ការទូរទាត់វិក្កយបត្រ
- ការទូរទាត់វិក្កយបត្រ (ជាកញ្ចប់)
- ការបញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទ
- ការបញ្ចូលទឹកប្រាក់កាតទូរស័ព្ទ (ជាកញ្ចប់)

- ពិនិត្យអត្រាប្តូរប្រាក់
- ពិនិត្យព័ត៌មានគណនីសន្សំ ដូចជា សមតុល្យគណនី របាយការណ៍គណនី ទាញយករបាយការណ៍គណនី
- ពិនិត្យព័ត៌មានគណនីបញ្ញើមានកាលកំណត់
- បើកគណនីបញ្ញើមានកាលកំណត់
- បញ្ជូនសំណើស្នើសុំបិទគណនីបញ្ញើមានកាលកំណត់
- ពិនិត្យមើល បង្កើត និងលុបទម្រង់គំរូ
- ពិនិត្យមើល បង្កើត បញ្ឈប់ ដំណើរការ និងលុបកាលវិភាគ
- ពិនិត្យព័ត៌មានកម្ចី និងកាលវិភាគសងប្រាក់កម្ចី
- ស្នើសុំកម្ចី
- ស្នើសុំទិញមូលប្បទានប័ត្រ
- បញ្ឈប់ការទូទាត់មូលប្បទានប័ត្រ
- ពិនិត្យព័ត៌មានមូលប្បទានប័ត្រ
- ពិនិត្យព័ត៌មាននៃសេវាហិរញ្ញប្បទានពាណិជ្ជកម្ម
- ការគណនាប្រាក់បញ្ញើតាមកាលកំណត់
- ការគណនាប្រាក់កម្ចី និង
- មុខងារផ្សេងៗជាច្រើនទៀត។ល។

4. ការស្នើសុំប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេត

4.1. លក្ខខណ្ឌនៃការស្នើសុំប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេត

1). លោក-លោកស្រី អាចស្នើសុំប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេត ជាលាយលក្ខណ៍អក្សរនៅសាខាណាមួយរបស់ខេប៊ីប្រាសាក់ ឬ តាមរយៈបុគ្គលិករបស់ខេប៊ីប្រាសាក់ ឬ បញ្ជូនការស្នើសុំតាមរយៈ «ខេប៊ីប្រាសាក់ឧបភើរេតវេប»។

2). លោក-លោកស្រី ត្រូវមានគណនីប្រាក់បញ្ញើសន្សំជាមួយខេប៊ីប្រាសាក់ អាចជាគណនីសន្សំ ឬ គណនីចម្រើនគ្មានកាលកំណត់ ឬ គណនីសន្សំតាមលំដាប់ ឬ គណនីចរន្ត ឬ គណនីចរន្តព្រីមៀម ឬ គណនីសន្សំពាណិជ្ជករ។ល។ និងត្រូវរក្សាសមតុល្យអប្បបរមា (Minimum Balance) ទៅតាមប្រភេទគណនីនីមួយៗ។

3). អ្នកមានសិទ្ធិស្នើសុំ គឺជាម្ចាស់គណនី ឬ អ្នកមានសិទ្ធិក្នុងគណនី ឬ យោងតាមសេចក្តីសម្រេចចេញពីក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនជាដើម។

4.2. ប្រភេទអ្នកប្រើប្រាស់ សេវាខេប៊ីប្រាសាក់ឧបភើរេត (Type of User)

អ្នកប្រើប្រាស់ (User Type) សេវាខេប៊ីប្រាសាក់ឧបភើរេត ចែកចេញជា 05 ប្រភេទរួមមាន៖

ល.រ	ប្រភេទអ្នកប្រើប្រាស់	តួនាទី	អ្នកមានសិទ្ធិ
1	អ្នកពិនិត្យ (Viewer)	មានសិទ្ធិត្រឹមពិនិត្យព័ត៌មានគណនី ឬ ទាញរបាយការណ៍គណនី	ជា ម្ចាស់គណនី (Account Holder) ឬ អ្នកមានសិទ្ធិក្នុងគណនី (Account's Signatory) ឬ ភាគីទីបី (Third Party)
2	អ្នកធ្វើប្រតិបត្តិការ (Maker)	ជាអ្នកបង្កើតប្រតិបត្តិការនៅក្នុង «ខេប៊ីប្រាសាក់ឧបភើរេតវេប»	
3	អ្នកត្រួតពិនិត្យ (Checker)	ជាអ្នកត្រួតពិនិត្យរាល់ប្រតិបត្តិការដែលបានបញ្ជូនពី «អ្នកធ្វើប្រតិបត្តិការ (Maker)»	
4	អ្នកអនុម័ត (Authorizer)	ជាអ្នកធ្វើការអនុម័តប្រតិបត្តិការដែលបានបញ្ជូនពី «អ្នកត្រួតពិនិត្យ (Checker)»	
5	អ្នកអនុម័តចុងក្រោយ (Final Authorizer)	ជាអ្នកធ្វើការអនុម័តប្រតិបត្តិការដែលបានបញ្ជូនពី «អ្នកអនុម័ត Authorizer)» ដើម្បីបញ្ចប់ប្រតិបត្តិការ	ជាម្ចាស់គណនី (Account Holder) ឬ អ្នកមានសិទ្ធិក្នុងគណនី (Account's Signatory)

4.3. ការកំណត់បន្ទាត់អនុម័តប្រតិបត្តិការ (Authorization Line)

1). ក្នុងការស្នើសុំប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេត លោក-លោកស្រីត្រូវធ្វើការជ្រើសរើសយក Authorization Line ឬ Non-Authorization Line ដើម្បីធ្វើប្រតិបត្តិការតាមរយៈសេវាខេប៊ីប្រាសាក់ឧបភើរេត។

2). ករណីលោក-លោកស្រីជ្រើសរើសយក Authorization Line លោក-លោកស្រីត្រូវធ្វើការកំណត់សិទ្ធិអ្នកប្រើប្រាស់ (User) សេវាខេប៊ីប្រាសាក់ឧបភើរេត ផ្សេងៗទៀតរួមមាន អ្នកធ្វើប្រតិបត្តិការ (Maker) អ្នកត្រួតពិនិត្យ (Checker) និង/ឬ អ្នកអនុម័ត (Authorizer)។

3). ករណីលោក-លោកស្រីជ្រើសរើសយក Non-Authorization Line លោក-លោកស្រីមិនតម្រូវឱ្យធ្វើការកំណត់សិទ្ធិអ្នកប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេត ផ្សេងៗទៀតរួមមាន អ្នកធ្វើប្រតិបត្តិការ (Maker) អ្នកត្រួតពិនិត្យ (Checker) និង/ឬ អ្នកអនុម័ត (Authorizer) ដោយលោក-លោកស្រី គឺជាអ្នកធ្វើប្រតិបត្តិការ (Maker) និងជាអ្នកអនុម័តចុងក្រោយ (Final Authorizer) សម្រាប់គ្រប់ការធ្វើប្រតិបត្តិការតាមរយៈសេវាខេប៊ីប្រាសាក់ឧបភើរេត។

4.4. ការបើកដំណើរការសេវាខេប៊ីប្រាសាក់ឧបភើរេត (Activate KB PRASAC Corporate)

1). លោក-លោកស្រី (រួមទាំងអ្នកប្រើប្រាស់ផ្សេងទៀតដែលមានតួនាទីជា Maker, Checker, Authorizer, Viewer) ត្រូវធ្វើការបើកឱ្យដំណើរការសេវាខេប៊ីប្រាសាក់ឧបភើរេត (Activate KB PRASAC Corporate) ដោយខ្លួនឯង ទៅតាមតំណភ្ជាប់ (Activation Link) ដែលខេប៊ីប្រាសាក់ផ្ញើជូនតាមរយៈអ៊ីម៉ែល និង/ឬ លេខទូរស័ព្ទ។

2). លោក-លោកស្រីត្រូវបញ្ចូលព័ត៌មានឱ្យបានត្រឹមត្រូវទៅតាមព័ត៌មានតម្រូវពីប្រព័ន្ធ និងត្រូវធ្វើការកំណត់ **លេខសម្ងាត់ (Password)** ដោយខ្លួនឯង សម្រាប់ចូលទៅប្រើប្រាស់សេវាខេប៊ីប្រាសាក់ខបភើរេត។

4.5. ការចូលប្រើប្រាស់សេវាខេប៊ីប្រាសាក់ខបភើរេត

1). ដើម្បីចូលទៅប្រើប្រាស់សេវាខេប៊ីប្រាសាក់ខបភើរេត លោក-លោកស្រីត្រូវចូលទៅកាន់ Web browser ដោយបញ្ចូល https://corporate.kbprasacbank.com.kh

2). ត្រូវបញ្ចូលនូវ «អត្តលេខអ្នកប្រើប្រាស់/ User ID) ដែលលោក-លោកស្រីទទួលបានតាមរយៈអ៊ីម៉ែល ឬ SMS ពីខេប៊ីប្រាសាក់

3). ត្រូវបញ្ចូល **លេខសម្ងាត់(Password)** ដែលបានបង្កើតដោយខ្លួនឯង និង

4). បញ្ចូល លេខកូដ OTP ដែលត្រូវបានបង្កើតឡើងដោយស្វ័យប្រវត្តិតាមរយៈ «ខេប៊ីប្រាសាក់ខបភើរេតអេប/KB PRASAC Corporate App» នៅលើទូរស័ព្ទឱ្យបានត្រឹមត្រូវ។

4.6. ការស្នើសុំភ្ជាប់គណនីបញ្ញើសន្សំ

1). លោក-លោកស្រីអាចធ្វើការស្នើសុំភ្ជាប់គណនីបន្ថែម ដោយជ្រើសរើសកម្រិតសិទ្ធិប្រើប្រាស់គណនី “ពេញលេញ/Full Access” ឬ “ពិនិត្យព័ត៌មាន/View Only” ជាលាយលក្ខណ៍អក្សរនៅសាខាណាមួយរបស់ខេប៊ីប្រាសាក់។

2). ការស្នើសុំភ្ជាប់គណនីបន្ថែម ត្រូវគោរពទៅតាមលក្ខខណ្ឌចុះហត្ថលេខានៃគណនី (Account Signing Condition) ដែលស្នើសុំភ្ជាប់នោះ។

4.7. ការស្នើសុំដកគណនីបញ្ញើសន្សំ

1). លោក-លោកស្រីអាចធ្វើការស្នើសុំដកគណនីចេញពីសេវាខេប៊ីប្រាសាក់ខបភើរេត ជាលាយលក្ខណ៍អក្សរនៅតាមសាខាណាមួយរបស់ខេប៊ីប្រាសាក់។

2). ការស្នើសុំដកគណនី ត្រូវគោរពតាមលក្ខខណ្ឌចុះហត្ថលេខានៃគណនី (Account Signing Condition)។

4.8. ការស្នើសុំភ្ជាប់គណនីបញ្ញើមានកាលកំណត់

1). គណនីបញ្ញើមានកាលកំណត់ (Term Deposit Account) នឹងត្រូវបានភ្ជាប់ដោយស្វ័យប្រវត្តិទៅក្នុងសេវាខេប៊ីប្រាសាក់ខបភើរេត ករណី **គណនីប្រភព** ត្រូវបានភ្ជាប់នៅក្នុងសេវាខេប៊ីប្រាសាក់ខបភើរេត។

2). ករណីគណនីប្រភព ត្រូវបានដកចេញពីសេវាខេប៊ីប្រាសាក់ខបភើរេត នោះគណនីបញ្ញើមានកាលកំណត់ (Term Deposit Account) នឹងត្រូវបានដកចេញដោយស្វ័យប្រវត្តិ។

4.9. ការស្នើសុំភ្ជាប់គណនីកម្ចី

1). គណនីកម្ចី (Loan Account) ត្រូវបានភ្ជាប់ដោយស្វ័យប្រវត្តិទៅក្នុងសេវាខេប៊ីប្រាសាក់ខបភើរេត ករណីអ្នកឈរឈ្មោះខ្ចី ឬ អ្នករួមខ្ចីបានចុះឈ្មោះប្រើប្រាស់សេវាខេប៊ីប្រាសាក់ខបភើរេត ដោយភ្ជាប់គណនីសន្សំសម្រាប់ទូទាត់សងកម្ចី ទៅក្នុងសេវាខេប៊ីប្រាសាក់ខបភើរេត។

2). ករណីគណនីសន្សំសម្រាប់ទូទាត់សងកម្ចី ត្រូវបានដកចេញពីសេវាខេប៊ីប្រាសាក់ខបភើរេត នោះគណនីកម្ចី នឹងដកចេញដោយស្វ័យប្រវត្តិ។

4.10. ការស្នើសុំលេខកូដសម្ងាត់ថ្មីករណីភ្លេច (Password) និង/ឬ អត្តលេខអ្នកប្រើប្រាស់ (User ID)

លោក-លោកស្រី អាចស្នើសុំលេខកូដសម្ងាត់ថ្មីករណីភ្លេច (Password) និង/ឬ អត្តលេខអ្នកប្រើប្រាស់ (User ID) ជាលាយលក្ខណ៍អក្សរនៅតាមសាខារបស់ខេប៊ីប្រាសាក់ ដោយត្រូវភ្ជាប់ជាមួយឯកសារបញ្ជាក់អត្តសញ្ញាណ។

4.11. ការស្នើសុំកែប្រែព័ត៌មានអ្នកប្រើប្រាស់ និង/ឬ សិទ្ធិអ្នកប្រើប្រាស់សេវាខេប៊ីប្រាសាក់ខបភើរេត

1) លោក-លោកស្រី អាចស្នើសុំកែប្រែព័ត៌មានផ្ទាល់ខ្លួន រួមមានលេខទូរស័ព្ទ និង/ឬ អ៊ីម៉ែល និង/ឬ ដកសិទ្ធិ និង/ឬ បន្ថែមសិទ្ធិអ្នកប្រើប្រាស់សម្រាប់ Maker, Checker, Authorizer បាន នៅតាមសាខាណាមួយរបស់ខេប៊ីប្រាសាក់ ឬ តាមរយៈមន្ត្រីពាក់ព័ន្ធផ្នែកលក់។
2) ការស្នើសុំត្រូវគោរពទៅតាមលក្ខខណ្ឌកំណត់ដោយខេប៊ីប្រាសាក់។

5. កម្រិតសិទ្ធិប្រើប្រាស់គណនីភ្ជាប់សេវាខេប៊ីប្រាសាក់ខបភើរេត

1) លោក-លោកស្រីអាចជ្រើសរើសកម្រិតសិទ្ធិប្រើប្រាស់គណនីភ្ជាប់សេវាខេប៊ីប្រាសាក់ខបភើរេត ដោយត្រូវកំណត់នៅលើពាក្យស្នើសុំប្រើប្រាស់សេវាខេប៊ីប្រាសាក់ខបភើរេត ឱ្យបានត្រឹមត្រូវទៅតាមជម្រើសដូចខាងក្រោម៖
   - **«ពេញលេញ / Full Access»**៖ ជាកម្រិតសិទ្ធិនៃការប្រើប្រាស់គណនី នៅក្នុងសេវាខេប៊ីប្រាសាក់ខបភើរេត ដែលអនុញ្ញាតឱ្យលោក-លោកស្រីអាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុ (ផ្ទេរប្រាក់/ទូទាត់...) និងប្រតិបត្តិការមិនមែនហិរញ្ញវត្ថុបាន (ពិនិត្យព័ត៌មានគណនី កម្ចី អត្រាប្តូរប្រាក់ ឬ ព័ត៌មានផ្សេងៗ)
   - **«ពិនិត្យព័ត៌មាន / View Only»**៖ ជាកម្រិតសិទ្ធិនៃការប្រើប្រាស់គណនី នៅក្នុងសេវាខេប៊ីប្រាសាក់ខបភើរេត ដែលអាចត្រឹមតែពិនិត្យព័ត៌មានគណនី ព័ត៌មានកម្ចី អត្រាប្តូរប្រាក់ ឬ ព័ត៌មានផ្សេងៗ ដោយមិនអាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុ (ផ្ទេរប្រាក់/ទូទាត់...) បានឡើយ។
2) ករណីលោក-លោកស្រី ចង់ប្តូរកម្រិតសិទ្ធិប្រើប្រាស់គណនីពី **«ពេញលេញ / Full Access»** ទៅ/មក **«ពិនិត្យព័ត៌មាន / View Only»** លោក-លោកស្រី អាចធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរនៅតាមសាខាខេប៊ីប្រាសាក់ណាមួយដែលនៅជិតបំផុត។

6. ម៉ោងប្រតិបត្តិការ

6.1. លោក-លោកស្រី អាចធ្វើប្រតិបត្តិការតាមរយៈសេវាខេប៊ីប្រាសាក់ខបភើរេត បាន 24 ម៉ោង ជាប្រចាំថ្ងៃ (24/7) លើកលែងតែមានការផ្អាកជាបណ្តោះអាសន្នដោយមានការជូនដំណឹងពី ខេប៊ីប្រាសាក់។

6.2. ខេប៊ីប្រាសាក់ នឹងធ្វើការជូនដំណឹងដល់ លោក-លោកស្រី ករណីមានការផ្អាកប្រតិបត្តិការដើម្បីជួសជុល ឬ ធ្វើបច្ចុប្បន្នភាពប្រព័ន្ធ។

6.3. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការផ្អាកប្រតិបត្តិការពេលមានបញ្ហាផ្សេងៗ ឬ ពេលមានការចាំបាច់ណាមួយ។

7. រូបិយប័ណ្ណ និងអត្រាប្តូរប្រាក់

7.1. លោក-លោកស្រី អាចធ្វើប្រតិបត្តិការតាមរយៈសេវាខេប៊ីប្រាសាក់ខបភើរេត ជាមួយរូបិយប័ណ្ណចំនួន 02 (ពីរ) ប្រភេទ រួមមាន៖
   - ប្រាក់រៀល (KHR) និង
   - ប្រាក់ដុល្លារអាមេរិក (USD)

7.2. រាល់ប្រតិបត្តិការឆ្លងរូបិយប័ណ្ណ អត្រាប្តូរប្រាក់ត្រូវយោងទៅតាមអត្រាប្តូរប្រាក់ជាក់ស្តែងរបស់ ខេប៊ីប្រាសាក់ នៅក្នុងថ្ងៃ និងម៉ោងនៃការធ្វើប្រតិបត្តិការ ឬ យោងតាមអត្រាប្តូរប្រាក់នៃធនាគារអ្នកទទួលផល ករណីផ្ទេរឆ្លងរូបិយប័ណ្ណទៅគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុផ្សេង។

8. ទំហំកំណត់នៃប្រតិបត្តិការ និងកម្រៃសេវា

8.1. លោក-លោកស្រី អាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុបាននៅពេលណាដែលគណនីរបស់ លោក-លោកស្រី មានសមតុល្យគ្រប់គ្រាន់ និងត្រូវគោរពទៅតាមទំហំកំណត់ដោយខេប៊ីប្រាសាក់។

8.2. លោក-លោកស្រី យល់ព្រម បង់កម្រៃសេវាផ្សេងៗ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ និង/ឬ ធ្វើប្រតិបត្តិការតាមរយៈសេវាខេប៊ីប្រាសាក់ឧបភើរេត ព្រមទាំងយល់ព្រមឱ្យខេប៊ីប្រាសាក់ ទូទាត់កម្រៃសេវាដោយផ្ទាល់ចេញពីគណនីរបស់ លោក-លោកស្រី ដោយពុំចាំបាច់ធ្វើការជូនដំណឹងជាមុនឡើយ។

8.3. លោក-លោកស្រីអាចស្វែងរកព័ត៌មានស្តីអំពីកម្រៃសេវា និង/ឬ ទំហំកំណត់ក្នុងមួយប្រតិបត្តិការ និងក្នុងមួយថ្ងៃទៅតាមប្រភេទប្រតិបត្តិការនីមួយៗ នៅលើគេហទំព័រផ្លូវការរបស់ ខេប៊ីប្រាសាក់ និង/ឬ គ្រប់សាខាខេប៊ីប្រាសាក់ និង/ឬ សេវាខេប៊ីប្រាសាក់ឧបភើរេត។

9. សារជូនដំណឹងស្តីពីប្រតិបត្តិការកើតឡើងក្នុងគណនី (Push Notification)

លោក-លោកស្រី នឹងទទួលបានសារជូនដំណឹងតាមរយៈសេវាខេប៊ីប្រាសាក់ឧបភើរេត (Push Notification) ស្តីអំពីប្រតិបត្តិការហិរញ្ញវត្ថុ ដែលបានកើតឡើងនៅក្នុងគណនីរបស់លោក-លោកស្រី លើកលែងតែមានភាពរអាក់រអួលពីប្រព័ន្ធ។

10. លក្ខណៈពិសេសផ្សេងៗពីប្រតិបត្តិការតាមរយៈសេវាខេប៊ីប្រាសាក់ឧបភើរេត

10.1. ការបញ្ចូលលេខសម្ងាត់ (Password) ឬ លេខកូដ OTP ខុស 03 ដង នោះសេវាខេប៊ីប្រាសាក់ឧបភើរេត នឹងត្រូវបានបង្ខាំងដោយស្វ័យប្រវត្តិ។

10.2. លោក-លោកស្រីអាចទាក់ទងមក ខេប៊ីប្រាសាក់ តាមរយៈលេខ 023/086 999 911 ឬ អញ្ជើញមកសាខាខេប៊ីប្រាសាក់ ណាមួយដើម្បីស្នើសុំដោះបង្ខាំង។

11. ការស្នើសុំបង្ខាំង ឬ ដោះបង្ខាំងសេវាខេប៊ីប្រាសាក់ឧបភើរេត

11.1. លោក-លោកស្រី អាចស្នើសុំបង្ខាំង (Block) អ្នកប្រើប្រាស់ (User ID) ឬ សេវាខេប៊ីប្រាសាក់ឧបភើរេត តាមរយៈទូរស័ព្ទមកមន្ត្រីបម្រើសេវាអតិថិជន (023/086 999 911) ឬ អញ្ជើញមកកាន់សាខាខេប៊ីប្រាសាក់ណាមួយដែលនៅជិតបំផុត។

11.2. ករណីស្នើសុំដោះបង្ខាំង (Unblock) សេវាខេប៊ីប្រាសាក់ឧបភើរេត ឬ អ្នកប្រើប្រាស់ លោក-លោកស្រី ត្រូវអញ្ជើញមកស្នើសុំជាលាយលក្ខណ៍អក្សរនៅតាមសាខាខេប៊ីប្រាសាក់ណាមួយដែលនៅជិតបំផុត។

12. ការបញ្ឈប់ការប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេត

លោក-លោកស្រី អាចស្នើសុំបញ្ឈប់ការប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេត ជាលាយលក្ខណ៍អក្សរបាន ដោយត្រូវអញ្ជើញទៅកាន់សាខាខេប៊ីប្រាសាក់ ណាមួយដែលនៅជិតបំផុត។

13. សុវត្ថិភាពលើការប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេត

13.1. សុវត្ថិភាពលើទូរស័ព្ទ កុំព្យូទ័រ ឬ ឧបករណ៍ផ្សេង

13.1.1. សូមកំណត់លេខសម្ងាត់ (Password) ឬ កំណត់ការស្កេនស្នាមខ្ទៅដៃ/ផ្ទៃមុខ (Fingerprint / Facial Recognition) ដើម្បីការពារទូរស័ព្ទ ឬ កុំព្យូទ័រ ឬ ឧបករណ៍ពាក់ព័ន្ធ របស់លោក-លោកស្រី ពីការចូលមើល ឬ ប្រើប្រាស់ពីបុគ្គលផ្សេងដោយគ្មានការអនុញ្ញាត។

13.1.2. មិនត្រូវផ្តល់ ឬ បង្ហាញ **លេខសម្ងាត់ (Password)** ឬ អនុញ្ញាតឱ្យបុគ្គលណាម្នាក់ធ្វើការកំណត់ **លេខសម្ងាត់ ឬ ស្កេនស្នាមខ្ទៅដៃ / ផ្ទៃមុខ** ឬ ចូលប្រើប្រាស់ទូរស័ព្ទចល័ត ឬ កុំព្យូទ័រ ឬ ឧបករណ៍ពាក់ព័ន្ធជំនួសលោក-លោកស្រីជាដាច់ខាត បើទោះបីជាបុគ្គលនោះជា អ្នករួមគណនី ឬ សាច់ញាតិ ឬ មិត្តភក្តិ ឬ បុគ្គលិកខេប៊ីប្រាសាក់ ក៏ដោយ។ល។

13.1.3. មិនត្រូវកត់លេខសម្ងាត់ (Password) ដើម្បីចូលទូរស័ព្ទចល័ត ឬ កុំព្យូទ័រ ឬ ឧបករណ៍ពាក់ព័ន្ធ ឬ កម្មវិធីផ្សេងៗ នៅក្នុងទូរស័ព្ទចល័ត ឬ កុំព្យូទ័រ ជាដាច់ខាត។

13.1.4. ត្រូវប្រាកដថារាល់ការបញ្ចូល **លេខសម្ងាត់ (Password)** ដើម្បីចូលប្រើប្រាស់ទូរស័ព្ទ ឬ កុំព្យូទ័រ ឬ ឧបករណ៍ពាក់ព័ន្ធរបស់លោក-លោកស្រី មិនត្រូវបានលួចមើល ឬ ដឹងដោយបុគ្គលណាម្នាក់ឡើយ។

13.1.5. ត្រូវធ្វើការផ្លាស់ប្តូរ **លេខសម្ងាត់ (Password)** ទូរស័ព្ទចល័ត ឬ កុំព្យូទ័រ ឬ ឧបករណ៍ពាក់ព័ន្ធរបស់លោក-លោកស្រី ឱ្យបានញឹកញាប់ ឬ ករណីសង្ស័យថាលេខសម្ងាត់ត្រូវបានដឹងដោយបុគ្គលណាម្នាក់។

13.1.6. សូមកុំប្រើទូរស័ព្ទចល័ត ឬ កុំព្យូទ័រ ឬ ឧបករណ៍ពាក់ព័ន្ធ ដែលភ្ជាប់សេវាខេប៊ីប្រាសាក់ឧបភើរេត ជាមួយសេវាអ៊ីនធឺណិតសាធារណៈ ឬ ប្រើរួមជាមួយអ្នកដទៃ ដើម្បីចៀសវាងពីការបន្លំលួចដោយ Hacker ។

13.1.7. មិនត្រូវភ្ជាប់ប្រព័ន្ធ ឬ បញ្ចូលកម្មវិធី ដែលមិនស្គាល់ក្នុងទូរស័ព្ទ ឬ កុំព្យូទ័រ ឬ ឧបករណ៍ពាក់ព័ន្ធ ឡើយ។ ករណីបានភ្ជាប់ ត្រូវផ្តាច់ ឬ លុបចេញ និងសម្អាតភ្លាមៗ ដើម្បីចៀសវាងការឆ្លងមេរោគ ឬ ការបន្លំលួចប្រាក់របស់លោក-លោកស្រី (Virus and/or Hacker)។

13.1.8. ត្រូវមានកម្មវិធីកម្ចាត់មេរោគ និងធ្វើបច្ចុប្បន្នភាពឱ្យបានទៀងទាត់លើកុំព្យូទ័រ ឬ ឧបករណ៍ពាក់ព័ន្ធ របស់លោក-លោកស្រី។

13.1.9. ត្រូវដំឡើងកម្មវិធីខេប៊ីប្រាសាក់ឧបភើរេតអេប (KB PRASAC Corporate App) និងធ្វើបច្ចុប្បន្នភាពកម្មវិធីទូរស័ព្ទ ដោយផ្ទាល់ពី Google Play Store ឬ App Store។

13.1.10. សូមកុំទុកទូរស័ព្ទចល័ត ឬ កុំព្យូទ័រ ឬ ឧបករណ៍ពាក់ព័ន្ធ ដែលកំពុងបើកសេវាខេប៊ីប្រាសាក់ឧបភើរេត ចោលនៅទីសាធារណៈ និងត្រូវ **ចាក់សោទូរស័ព្ទ (Lock Phone)** ឬ កុំព្យូទ័រភ្លាមៗករណីឈប់ប្រើប្រាស់។

13.1.11. សូមចាកចេញ (Log out) លុបប្រតិបត្តិការ (Clear History) និងបិទកម្មវិធី Internet Browser ឬ បិទសេវាខេប៊ីប្រាសាក់ឧបភើរេត នៅពេល លោក-លោកស្រីធ្វើប្រតិបត្តិការរួចរាល់។

13.1.12. ក្នុងករណីលោក-លោកស្រី លក់ ឬ ជួសជុល ឬ ផ្ទេរទូរស័ព្ទ ឬ កុំព្យូទ័រ ឱ្យអ្នកផ្សេង លោក-លោកស្រីត្រូវលុបកម្មវិធីខេប៊ីប្រាសាក់ឧបភើរេតអេប ឬ ព័ត៌មានពាក់ព័ន្ធផ្សេងៗចេញពីក្នុងទូរស័ព្ទ ឬ កុំព្យូទ័រ ឱ្យបានរួចរាល់ជាមុន។

13.1.13. ករណីបាត់ទូរស័ព្ទ ឬ កុំព្យូទ័រ ឬ សង្ស័យមានអ្នកផ្សេងស្គាល់លេខសម្ងាត់ចូលប្រើប្រាស់ទូរស័ព្ទ ឬ កុំព្យូទ័រត្រូវជូនដំណឹងមក ខេប៊ីប្រាសាក់ ជាបន្ទាន់តាមរយៈលេខ 023/086 999 911 ដើម្បីបង្ខាំងសេវាខេប៊ីប្រាសាក់ឧបភើរេត ឬ ចាត់វិធានការផ្សេងៗតាមលក្ខណៈបច្ចេកទេស ដើម្បីទប់ស្កាត់ការបន្លំធ្វើប្រតិបត្តិការ។

13.2. សុវត្ថិភាពលើអត្តលេខអ្នកប្រើប្រាស់ និងលេខសម្ងាត់

13.2.1. សូមចងចាំអត្តលេខអ្នកប្រើប្រាស់ និងលេខសម្ងាត់ (Password) របស់លោក-លោកស្រី និងមិនត្រូវកត់ត្រាលើអ្វីមួយ ឬ ឱ្យអ្នកដទៃដឹងឡើយ។

13.2.2. សូមរក្សាអត្តលេខអ្នកប្រើប្រាស់ (User ID) ឬ លេខសម្ងាត់ (Password) ឬ លេខកូដ OTP និងព័ត៌មានផ្សេងៗរបស់លោក-លោកស្រីឱ្យមានសុវត្ថិភាព។ រាល់ការខូចខាតដែលកើតចេញពីការធ្វេសប្រហែសក្នុងការរក្សាព័ត៌មានសម្ងាត់ខាងលើ គឺជាការទទួលខុសត្រូវទាំងស្រុងរបស់លោក-លោកស្រី។

13.2.3. សូមកុំផ្តល់ ឬ ផ្ញើអត្តលេខអ្នកប្រើប្រាស់ ឬ លេខសម្ងាត់ (Password) ឬ លេខកូដ OTP ឬ ព័ត៌មានផ្ទាល់ខ្លួនដល់នរណាម្នាក់ឡើយ ទោះដោយផ្ទាល់មាត់ ឬ តាមរយៈផ្ញើសារអេឡិចត្រូនិកអាចជាអ៊ីម៉ែល Facebook Messenger, Telegram... ជាដើម។

13.2.4. សូមកុំប្រើ ថ្ងៃខែឆ្នាំកំណើត ឬ លេខទូរស័ព្ទ ឬ លេខគណនី ឬ លេខអត្តសញ្ញាណប័ណ្ណ ឬ លេខរៀងដែលងាយស្រួលចាំ ឬ ស្រួលស្មានដឹង (ឧ. 111111 ឬ 123456...) មកធ្វើជា លេខសម្ងាត់ (Password) ដើម្បីចូលប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេតឡើយ។

13.2.5. ត្រូវធានាឱ្យច្បាស់ថា រាល់ពេល លោក-លោកស្រី បញ្ចូលអត្តលេខអ្នកប្រើប្រាស់ (User ID) ឬ លេខសម្ងាត់ (Password) ដើម្បីចូលប្រើប្រាស់សេវា គឺមិនត្រូវបានអ្នកដទៃឃ្លាំមើល ឬ ក៏មានមនុស្សនៅក្បែរអ្នកឡើយ។

13.2.6. សូមធ្វើការផ្លាស់ប្តូរលេខសម្ងាត់ (Password) ឱ្យបានញឹកញាប់ និងក្នុងករណីសង្ស័យថា លេខសម្ងាត់ (Password) ត្រូវបានដឹងដោយអ្នកដទៃ។

13.2.7. លោក-លោកស្រី គួរកំណត់លេខសម្ងាត់ (Password) ចូលប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេតឱ្យខុសពីលេខសម្ងាត់ (Password) បើកសោទូរស័ព្ទ ឬ កុំព្យូទ័ររបស់ខ្លួន។

13.2.8. ត្រូវជូនដំណឹងមក ខេប៊ីប្រាសាក់ ជាបន្ទាន់ប្រសិនបើ លោក-លោកស្រី ភ្លេចលេខសម្ងាត់ (Password) និង/ឬ អត្តលេខអ្នកប្រើប្រាស់ (User ID) ឬ សង្ស័យអ្នកផ្សេងបានដឹង។

13.3. សារបោកបញ្ឆោតតាមរយៈអ៊ីម៉ែល ឬ ទូរស័ព្ទ

13.3.1. សូមចូលប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេត តាមរយៈអាសយដ្ឋាន https://corporate.kbprasacbank.com.kh តែមួយគត់។ សូមកុំចុចលើអាសយដ្ឋានតំណភ្ជាប់ (Hyperlink) ពីវេបសាយដទៃ។

13.3.2. សូមប្រុងប្រយ័ត្នការបោកបញ្ឆោតយកព័ត៌មាន តាមរយៈទូរស័ព្ទ អ៊ីម៉ែល វេបសាយត៍ កម្មវិធីដែលលោតផ្ទាំងមក (pop-up window) ឬ សារ (SMS) ដែលជាល្បិច ឱ្យ លោក-លោកស្រី បញ្ចូលព័ត៌មានសំខាន់ៗ ដូចជា៖ អត្តលេខអ្នកប្រើប្រាស់ (User ID) ឬ លេខសម្ងាត់ (Password) ឬ លេខកូដ OTP ឬ លេខទូរស័ព្ទ (Phone) ឬ ថ្ងៃខែឆ្នាំកំណើត (Date of Birth) ឬ ព័ត៌មានផ្ទាល់ខ្លួនផ្សេងៗជាដើម។ល។

13.3.3. ខេប៊ីប្រាសាក់ នឹងមិនស្នើសុំ លោក-លោកស្រី ឱ្យប្រាប់ពី លេខសម្ងាត់ (Password) និង/ឬ លេខកូដ OTP ដើម្បីចូលប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេតឡើយ ទោះបីជាស្នើសុំដោយផ្ទាល់មាត់ ឬ ទូរស័ព្ទ ឬ អ៊ីម៉ែល ឬ តាមមធ្យោបាយទំនាក់ទំនងណាមួយឡើយ។

13.3.4. ប្រសិនបើ លោក-លោកស្រី ទទួលបានអ៊ីម៉ែល ឬ សារទូរស័ព្ទ ឬ ការហៅទូរស័ព្ទ ដែលស្នើសុំព័ត៌មានខាងលើ សូមលុបចោល ឬ បដិសេធជាបន្ទាន់ និង/ឬ មិនត្រូវចុចលើតំណភ្ជាប់បណ្តាញ (Link) ឬ បើកឯកសារភ្ជាប់ណាមួយដែលមាននៅក្នុងអ៊ីម៉ែលនោះឡើយ។

13.3.5. ប្រសិនបើ លោក-លោកស្រី មានចម្ងល់ ឬ ក៏មានមន្ទិលសង្ស័យលើវេបសាយត៍ ឬ អ៊ីម៉ែលណាមួយ សូមទាក់ទងមកយើងខ្ញុំតាមរយៈ info@kbprasacbank.com.kh ឬ ទូរស័ព្ទលេខ 023/086 999 911។

14. សិទ្ធិ និងកាតព្វកិច្ចរបស់អតិថិជន

14.1. លោក-លោកស្រី ត្រូវធានាថាគ្រប់ព័ត៌មានដែលបានផ្តល់មក ខេប៊ីប្រាសាក់ ជាព័ត៌មានត្រឹមត្រូវ និង ថ្មីបំផុត។ ករណី លោក-លោកស្រី ផ្តល់ព័ត៌មានមិនពិត ឬ ក្លែងក្លាយ នោះ លោក-លោកស្រី ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់។

14.2. លោក-លោកស្រី ត្រូវធ្វើការត្រួតពិនិត្យកម្រៃសេវា និងព័ត៌មាននៃការទូទាត់ឱ្យបានត្រឹមត្រូវមុននឹងបញ្ជាការទូទាត់នៅក្នុងសេវាខេប៊ីប្រាសាក់ឧបភើរេត។ រាល់ការបញ្ចូលព័ត៌មាន ឬ លេខគណនីខុស ឬ ផ្ទេរសមតុល្យលើស ឬ ខ្វះ ជាដើម ជាការទទួលខុសត្រូវទាំងស្រុងរបស់លោក-លោកស្រី។

14.3. លោក-លោកស្រី ត្រូវទទួលខុសត្រូវលើការប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេត។ រាល់ការបាត់បង់ទឹកប្រាក់ក្នុងគណនីផ្ទាល់ខ្លួន ឬ គណនីរបស់អ្នកផ្សេង ដែលប្រព្រឹត្តដោយចេតនា ឬ អចេតនា ឬ ដោយការធ្វេសប្រហែស ឬ ដោយការសាកល្បងធ្វើប្រតិបត្តិការផ្សេងៗ ការលុកលុយរុករក ការកែបន្លំទិន្នន័យ ការលួចបន្លំដោយផ្ទាល់ ឬ ដោយប្រយោលតែម្នាក់ឯង ឬ ដោយមានការចូលរួមពីអ្នកដទៃ លោក-លោកស្រី ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

14.4. លោក-លោកស្រី យល់ព្រមដោយឥតលក្ខខណ្ឌក្នុងការទូទាត់សំណងមក ខេប៊ីប្រាសាក់ ករណីមានការប្តឹងតវ៉ា ការទាមទារ ការទទួលខុសត្រូវ ការខាតបង់ ឬ ការចំណាយផ្សេងៗ ដែលខេប៊ីប្រាសាក់ទទួលរងទាក់ទងនឹងប្រតិបត្តិការសេវាខេប៊ីប្រាសាក់ឧបភើរេត ដោយការអនុវត្តបំពានរបស់ លោក-លោកស្រី លើលក្ខខណ្ឌនៃការប្រើប្រាស់សេវាកម្មនេះ រួមទាំងការខកខានមិនបានចាត់វិធានការទប់ស្កាត់ ការធ្វើប្រតិបត្តិការដោយគ្មានការអនុញ្ញាត ឬ ប្រតិបត្តិការក្លែងបន្លំ។ល។

14.5. លោក-លោកស្រី ត្រូវធានាពីការរក្សាសុវត្ថិភាពទូរស័ព្ទ និងព័ត៌មានសម្ងាត់ ដើម្បីចូលប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេត ដូចជាលេខសម្ងាត់ និងព័ត៌មានផ្ទាល់ខ្លួន។ល។

14.6. លោក-លោកស្រី ត្រូវធានាថាបានដំឡើង ឬ ធ្វើបច្ចុប្បន្នភាព កម្មវិធីខេប៊ីប្រាសាក់ឧបភើរេតអេប ដោយផ្ទាល់ពី Play Store ឬ App Store និងធានាថាបានប្រើប្រាស់ កម្មវិធីខេប៊ីប្រាសាក់ឧបភើរេតវេប ជំនាន់ថ្មីបំផុត ដែលបានដាក់ឱ្យប្រើប្រាស់ ឬ ធ្វើបច្ចុប្បន្នភាពពីខេប៊ីប្រាសាក់។

14.7. លោក-លោកស្រី ត្រូវជូនដំណឹងមក ខេប៊ីប្រាសាក់ ជាលាយលក្ខណ៍អក្សរឱ្យបានទាន់ពេលវេលា ក្នុងករណីមានការផ្លាស់ប្តូរលេខទូរស័ព្ទ អ៊ីម៉ែល និង/ឬ ព័ត៌មានផ្ទាល់ខ្លួនផ្សេងៗ ដែលបានផ្តល់មកខេប៊ីប្រាសាក់។ រាល់ការខាតបង់ ឬ ការពន្យារពេលផ្សេងៗដែលអាចកើតមកពីការខកខានមិនបានជូនដំណឹងមកខេប៊ីប្រាសាក់ ជាការទទួលខុសត្រូវទាំងស្រុងរបស់លោក-លោកស្រី។

14.8. លោក-លោកស្រីមិនត្រូវធ្វើប្រតិបត្តិការណាមួយ ដែលខុសច្បាប់ ឬ សកម្មភាពអាជីវកម្មណាមួយ ដែលត្រូវបានហាមឃាត់តាមរយៈសេវាខេប៊ីប្រាសាក់ឧបភើរេតឡើយ។

14.9. លោក-លោកស្រីមានសិទ្ធិក្នុងការផ្ទៀងផ្ទាត់ព័ត៌មាននៅក្នុងរបាយការណ៍គណនីរបស់ខ្លួន និងសាកសួរមកខេប៊ីប្រាសាក់ ក្នុងករណីមានភាពមិនប្រក្រតីណាមួយកើតឡើង។

14.10. ក្នុងករណី លោក-លោកស្រី មានបញ្ហាផ្សេងៗពាក់ព័ន្ធនឹងការប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេត លោក-លោកស្រី ត្រូវជូនដំណឹងជាបន្ទាន់មក ខេប៊ីប្រាសាក់ តាមរយៈទូរស័ព្ទ 023/086 999 911។

14.11. លោក-លោកស្រី ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគ្រប់ចំណុចនៅលើ **លក្ខខណ្ឌនៃការប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេត** នេះ។

15. សិទ្ធិ និងកាតព្វកិច្ចរបស់ខេប៊ីប្រាសាក់

15.1. ខេប៊ីប្រាសាក់មានសិទ្ធិផ្ទៀងផ្ទាត់ព័ត៌មានរបស់លោក-លោកស្រី និងសម្រេចក្នុងការផ្តល់ជូននូវសេវាខេប៊ីប្រាសាក់ឧបភើរេតជូនលោក-លោកស្រី។

15.2. ខេប៊ីប្រាសាក់នឹងអនុវត្តតាមការបញ្ជាលើប្រតិបត្តិការទូទាត់តាមរយៈសេវាខេប៊ីប្រាសាក់ឧបភើរេតរបស់លោក-លោកស្រី ប៉ុន្តែខេប៊ីប្រាសាក់ មិនទទួលខុសត្រូវ ក្នុងករណីដែល លោក-លោកស្រី បានបញ្ចូលព័ត៌មាន ឬ លេខគណនីខុស ឬ ផ្ទេរសមតុល្យលើស ឬ ខ្វះ ជាដើម។

15.3. ខេប៊ីប្រាសាក់ មានសិទ្ធិសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការស៊ើបអង្កេត បង្ខាំង ឬ បញ្ឈប់ការប្រើប្រាស់សេវាខេប៊ីប្រាសាក់ឧបភើរេតរបស់ លោក-លោកស្រី ដោយយោងលើច្បាប់/បទបញ្ញត្តិ ឬ ដីកាពីតុលាការ។

15.4. ខេប៊ីប្រាសាក់ នឹងរក្សាការសម្ងាត់នូវរាល់ព័ត៌មានរបស់ លោក-លោកស្រី លើកលែងមានការយល់ព្រមពី លោក-លោកស្រី ឬ ច្បាប់តម្រូវ ឬ មានដីកាពីតុលាការបង្គាប់ឱ្យបង្ហាញព័ត៌មានសម្ងាត់ទាំងនោះ។

15.5. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការកែប្រែ ឬ អនុវត្តការយកកម្រៃសេវាប្រចាំឆ្នាំ/ប្រចាំខែ និង/ឬ កម្រៃសេវាពាក់ព័ន្ធ លើការប្រើប្រាស់ និង/ឬ ធ្វើប្រតិបត្តិការតាមរយៈសេវាខេប៊ីប្រាសាក់ឌបភើរេត អាស្រ័យលើលក្ខខណ្ឌ និង ស្ថានភាពអាជីវកម្មជាក់ស្តែង។

15.6. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការធ្វើបច្ចុប្បន្នភាពជាប្រចាំលើសេវាខេប៊ីប្រាសាក់ឌបភើរេត ទៅជំនាន់ថ្មីៗ ដោយ ខេប៊ីប្រាសាក់អាចនឹង៖

- ដាក់បន្ថែមនូវមុខងារប្រតិបត្តិការថ្មីៗ ដោយយោងទៅតាមនិន្នាការទីផ្សារ និង/ឬ ការប្រែប្រួលបច្ចេកវិទ្យា ឬ
- លុប ឬ ផ្អាកជាបណ្តោះអាសន្នលើមុខងារណាមួយ ប្រសិនបើមានបញ្ហាបច្ចេកទេសណាមួយកើតឡើង ដែលអាចមានផលប៉ះពាល់ដល់ប្រព័ន្ធធនាគារ ឬ ក្នុងគោលបំណងថែទាំប្រព័ន្ធ ឬ ផ្សេងៗ។

15.7. នៅក្នុងដំណាក់កាលណាមួយខេប៊ីប្រាសាក់អាចនឹងជំរុញឱ្យ លោក-លោកស្រី ធ្វើបច្ចុប្បន្នភាពសេវាខេប៊ី ប្រាសាក់ឌបភើរេត មកជំនាន់ថ្មីចុងក្រោយបង្អស់ (Update Last Version) ដើម្បីបង្កើនសុវត្ថិភាព និងភាព ដូចគ្នាលើការប្រើប្រាស់សេវា។

15.8. ប្រសិនបើសេវាខេប៊ីប្រាសាក់ឌបភើរេតរបស់លោក-លោកស្រី មិនអាចប្រើប្រាស់បានដោយករណីប្រធានសក្តិ ខេប៊ីប្រាសាក់នឹងជួយដល់ លោក-លោកស្រី ក្នុងការរកដំណោះស្រាយ ឬ ផ្តល់ជំនួយការចាំបាច់ណាមួយ យោងលើហេតុផលជាក់ស្តែង ប៉ុន្តែខេប៊ីប្រាសាក់មិនទទួលខុសត្រូវទៅលើហេតុការណ៍ទាំងនោះទេ។

15.9. ខេប៊ីប្រាសាក់រក្សាសិទ្ធិក្នុងការផ្អាកប្រតិបត្តិការពេលមានបញ្ហាផ្សេងៗ និងពេលមានការចាំបាច់ជាដើម។

15.10. ខេប៊ីប្រាសាក់ផ្តល់លេខទូរស័ព្ទសម្រាប់បម្រើសេវាប្រឹក្សាអំពីសេវាកម្ម និងការរាយការណ៍ពីការភ្លេចលេខ សម្ងាត់ ឬ បញ្ហាផ្សេងៗដែលកើតមាន តាមរយៈលេខ 023/086 999 911។

16. ការកែប្រែកម្រៃសេវា ទំហំកំណត់ លក្ខខណ្ឌផ្សេងៗ និងការជូនដំណឹង

16.1. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការកែប្រែកម្រៃសេវា ទំហំកំណត់ និង/ឬ លក្ខខណ្ឌផ្សេងៗដែលត្រូវអនុវត្តចំពោះការ ប្រើប្រាស់សេវាខេប៊ីប្រាសាក់ឌបភើរេត របស់លោក-លោកស្រី ដោយខេប៊ីប្រាសាក់នឹងធ្វើការជូនដំណឹងទៅ លោក-លោកស្រីឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវនៃច្បាប់។

16.2. ក្នុងរយៈពេលនៃការជូនដំណឹងខាងលើ ករណីមិនមានការតវ៉ាពីលោក-លោកស្រី ត្រូវសន្មតថា លោក-លោក ស្រីបានយល់ព្រម និងទទួលយកការកែប្រែទាំងនោះមកអនុវត្តភ្លាមៗបន្ទាប់ពីការកែប្រែចូលជាធរមានដែលត្រូវ បានផ្សព្វផ្សាយតាមរយៈមធ្យោបាយណាមួយខាងក្រោម៖

1). តាមរយៈសាខារបស់ខេប៊ីប្រាសាក់ និង/ឬ
2). តាមរយៈវេបសាយត៍ និង/ឬ បណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ខេប៊ីប្រាសាក់ និង/ឬ
3). ការផ្ញើសារ និង/ឬ អ៊ីម៉ែលទៅកាន់លោក-លោកស្រី
4). តាមរយៈការផ្សព្វផ្សាយនៅលើទំព័រការសែត ទស្សនាវដ្តី កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល សេវាខេប៊ីប្រាសាក់ ឌបភើរេត ឬ មធ្យោបាយផ្សេងៗដែលខេប៊ីប្រាសាក់ បានជ្រើសរើស។ល។

16.3. លោក-លោកស្រីត្រូវបានសន្មតថាបានទទួលការជូនដំណឹងស្តីពីការកែប្រែខាងលើភ្លាមៗ បន្ទាប់ពីខេប៊ីប្រាសាក់បានធ្វើការចុះផ្សាយពីការកែប្រែព័ត៌មាននានារបស់ខ្លួនតាមរយៈមធ្យោបាយណាមួយក្នុងចំណោមមធ្យោបាយខាងលើ។

17. ការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

អនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ខេប៊ីប្រាសាក់ អាចនឹងពន្យារពេល ឬ មិនធ្វើប្រតិបត្តិការជូន លោក-លោកស្រី បាន ប្រសិនបើ ខេប៊ីប្រាសាក់ មានការជឿជាក់ដោយផ្អែកលើមូលហេតុដូចខាងក្រោម៖

- ❖ ខេប៊ីប្រាសាក់មានការសង្ស័យចំពោះប្រភពដើមនៃប្រាក់បញ្ញើនោះ
- ❖ ប្រតិបត្តិការ ឬ គណនីនោះមានទំនាក់ទំនង ឬ ពាក់ព័ន្ធដោយផ្ទាល់ ឬ ដោយប្រយោលជាមួយនឹងសកម្មភាពល្មើសច្បាប់ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ច្បាប់អន្តរជាតិ
- ❖ មានការបង្គាប់បញ្ជាពីតុលាការ ឬ ធនាគារជាតិ នៃ កម្ពុជា។ល។

18. ច្បាប់ និងការដោះស្រាយវិវាទ

18.1. លក្ខខណ្ឌប្រើប្រាស់នេះ ត្រូវបានគ្រប់គ្រង និងបកស្រាយដោយយោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

18.2. ករណីមានវិវាទកើតឡើង ភាគីទាំងពីរត្រូវដោះស្រាយដោយសន្តិវិធី។ ករណីវិវាទមិនអាចដោះស្រាយបានដោយសន្តិវិធី ឬ ក្រៅប្រព័ន្ធតុលាការ នោះវិវាទត្រូវដោះស្រាយទៅតាមប្រព័ន្ធតុលាការដោយយោងទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

18.3. លក្ខខណ្ឌផ្សេងៗដែលមិនមានចែងនៅក្នុង «**លក្ខខណ្ឌប្រើប្រាស់**» នេះ ត្រូវអនុវត្តតាមគោលនយោបាយរបស់ខេប៊ីប្រាសាក់ និង/ឬ ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

19. វិភាគភាព

ប្រសិនបើប្រការណាមួយនៃលក្ខខណ្ឌប្រើប្រាស់នេះ មិនអាចអនុវត្តបាន ឬ គ្មានសុពលភាពតាមផ្លូវច្បាប់ ប្រការទាំងនោះនឹងអស់សុពលភាពត្រឹមកម្រិតដែលប្រការនោះមិនអាចអនុវត្តបាន ឬ អសុពលភាពនៃប្រការនោះតែប៉ុណ្ណោះ ចំណែកប្រការផ្សេងៗទៀតនៃលក្ខខណ្ឌប្រើប្រាស់នេះនៅតែបន្តមានសុពលភាពអនុវត្តដដែល។

20. ភាសា

លក្ខខណ្ឌប្រើប្រាស់នេះ ត្រូវបានធ្វើឡើងជាភាសាខ្មែរ និងអង់គ្លេស។ ករណីមានចំណុចណាមួយរវាងអត្ថបទទាំងពីរមានន័យមិនស្រប ឬ មិនស៊ីគ្នា នោះអត្ថបទជាភាសាខ្មែរចាត់ទុកជាផ្លូវការ៕